មាត្រា ២ ._ ការទូទាត់ ៖

-ប្រាក់បេសកកម្មកំណត់ខ្ពស់បំផុតត្រឹម ១០ ថ្ងៃ លើកលែងមានករណីពិសេសដែលទាក់ទងនឹងការងារបច្ចេកទេសតែមិនត្រូវអោយលើសពី ១៥ ថ្ងៃ ។ បើលើសពីនេះចាំបាច់ត្រូវមានបញ្ជាបេសកកម្មបន្តតែក៏មិនអោយលើសពី ២០ ថ្ងៃក្នុង ១ខែ ។

-ប្រាក់ហូបចុក គិតតាមចំនួនថ្ងៃការងារ

-ប្រាក់ស្នាក់នៅដោះស្រាយជូនទៅតាមវិក្កយបត្រជាក់ស្តែង និងមានការបញ្ជាក់ត្រឹមត្រូវ ។ បើជារូបិយប័ណ្ណអន្តរជាតិ ច្រើនបំផុតត្រឹម ១០ ដុល្លារអាមេរិក ក្នុងម្នាក់-ថ្ងៃ ។

-ប្រាក់ហូបចុក និងស្នាក់នៅ ត្រូវកត់ត្រាក្នុងខ្ទង់ថវិកាតែមួយគឺ ជំពូក ១១-០២-០១-០៣ ។

-មធ្យោបាយធ្វើដំណើរ ( ក្នុងករណីគ្មានមធ្យោបាយរបស់រដ្ឋ ) ដោះស្រាយជូនតាមវិក្កយបត្រជាក់ស្តែង និងមានការបញ្ជាក់ត្រឹមត្រូវ ។

-រាល់ការទូទាត់ត្រូវអនុវត្តជាប្រាក់រៀល បើទោះបីមានមុខសញ្ញាចំណាយខ្លះជារូបិយប័ណ្ណបរទេសក៏ដោយ ។

មាត្រា ៣ ._ រាល់ខ្លឹមសារកំណត់ទាំងឡាយណាដែលផ្ទុយ នឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខា ធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលគ្រប់ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

**អនុក្រឹត្យលេខ ០៨ អនក្រ.បក**

**ស្តីពីការបង្កើតក្រុមអ្នកច្បាប់ និង នាយកដ្ឋាន**

**ទំនាក់ទំនងអន្តរជាតិ និង អាស៊ាន ចំណុះក្រសួងមហាផ្ទៃ**

****

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**ជំពូកទី ១**

**អំពីក្រុមអ្នកច្បាប់**

**មាត្រា ១ .-** បង្កើតក្រុមអ្នកច្បាប់របស់ក្រសួងមហាផ្ទៃ ចំណុះរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលមានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

-លើកផែនការតាក់តែងសេចក្តីព្រាងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សារាចរ បទបញ្ជាផ្សេងៗលើការងាររដ្ឋបាលដែនដី និងការងារនគរបាលជាតិ ដែលរៀបចំឡើងដោយអគ្គនាយកដ្ឋានចំណុះក្រសួងមហាផ្ទៃ ដើម្បីដាក់ជូនរដ្ឋមន្ត្រីពិនិត្យ និងសំរេច ។

-ត្រួតពិនិត្យ និងលើកយោបល់ស្នើសុំកែសំរួល ឬលុបចោលប្រកាស សារាចរ ដីកា និងបទបញ្ជាផ្សេងៗដែលអង្គភាពរដ្ឋបាលដែនដី ឬនគរបាលជាតិចំណុះក្រសួងមហាផ្ទៃចេញមិនស្របច្បាប់ ។

-ទទួលពិនិត្យសេចក្តីព្រាងកិច្ចសន្យានានា ដែលពាក់ព័ន្ធនឹងកិច្ចការរដ្ឋបាលដែនដី ឬកិច្ចការនគរបាលជាតិ ។

-ទទួលនិងសហការផ្សព្វផ្សាយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សារាចរ បទបញ្ជាផ្សេងៗដែលស្ថាប័ននានា ជូនមកក្រសួងមហាផ្ទៃ ។

-សហការទំនាក់ទំនងជាមួយស្ថាប័ននានា ក្នុងការតាក់តែងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សារាចរ បទបញ្ជាផ្សេងៗអោយបានស្របច្បាប់ និងធារ៉ាប់រ៉ង ដើម្បីលើកកំពស់ការអនុវត្តន៍ច្បាប់អោយមានប្រសិទ្ធភាព ។

-គ្រប់គ្រងបណ្ណាល័យរបស់ក្រសួង និងធ្វើការចែកផ្សាយសៀវភៅរាជកិច្ច ដែលទីស្តីការគណៈរដ្ឋមន្ត្រីបញ្ជូនមក ។

-ធ្វើការងារបូកសរុប គ្រប់គ្រងឯកសារ ការងារបុគ្គលិក សម្ភារគណនេយ្យរបស់ក្រុមអ្នកច្បាប់តាមការកំណត់របស់ក្រសួងមហាផ្ទៃ ។

មាត្រា ២ ._ ក្រុមអ្នកច្បាប់ [illegible] មានប្រធានក្រុម ០១ រូប និងមានអ្នកច្បាប់មួយចំនួនជាសមាជិកដែលជាមន្ត្រីមានក្របខ័ណ្ឌក្រសួង ។ នាយកដ្ឋាននីតិកម្មត្រូវរំសាយចោល ហើយមន្ត្រីនៃនាយកដ្ឋាននេះ ត្រូវចាត់អោយមកបំពេញការងារក្នុងក្រុមអ្នកច្បាប់វិញ ។

មាត្រា ៣ ._ ប្រធានក្រុមអ្នកច្បាប់មានឋានៈ និងបុព្វសិទ្ធិស្មើនឹងអនុរដ្ឋលេខាធិការ ។ ប្រធានក្រុមមានភារកិច្ចដឹកនាំ និងចាត់ចែងអនុវត្តតួនាទីភារកិច្ច ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ។

មាត្រា ៤ ._ រចនាសម្ព័ន្ធរបស់ក្រុមអ្នកច្បាប់មាន លេខាធិការដ្ឋានមួយរួមមាន ៖

-ការិយាល័យរដ្ឋបាល និង សរុប

-ការិយាល័យនីតិកម្ម

-ការិយាល័យទំនាក់ទំនងការងារយុត្តិធម៌

-ការិយាល័យបណ្ណាល័យ

## ជំពូកទី ២

## នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និង អាស៊ាន ចំណុះខុទ្ទកាល័យក្រសួងមហាផ្ទៃ

មាត្រា ៥ ._ តម្លើងការិយាល័យទំនាក់ទំនងអន្តរជាតិចំណុះខុទ្ទកាល័យក្រសួងមហាផ្ទៃ ទៅជានាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងអាស៊ាន ដែលមានតួនាទីភារកិច្ចដូចខាងក្រោម ៖

-សហការរៀបចំប្រជុំសិក្ខាសាលា និងពិធីផ្សេងៗជូនថ្នាក់ដឹកនាំក្រសួង ។

-រៀបចំបែបបទលិខិតឆ្លងដែន ទិដ្ឋាការ និងទំរង់បែបបទជូនថ្នាក់ដឹកនាំ និងគណៈប្រតិភូរបស់ក្រសួងមហាផ្ទៃ អញ្ជើញទៅបំពេញទស្សនកិច្ចនៅបរទេស ។

-ទំនាក់ទំនងជាមួយស្ថានទូត និងក្រសួងនានាលើការងារអន្តរជាតិ ។

-ចងក្រង និងធ្វើសេចក្តីព្រាង ព្រមទាំងរៀបចំពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលកម្ពុជា ជាមួយក្រសួងមហាផ្ទៃ នគរបាលជាតិ នៃប្រទេសនានា លើសកលលោក និងបកប្រែលិខិតស្នាមផ្សេងៗ ។

-ធ្វើទំនាក់ទំនងការងារជាមួយក្រសួងមហាផ្ទៃ និងអគ្គនគរបាលជាតិ នៃប្រទេសនានាលើការងារគ្រប់គ្រងរដ្ឋបាល ដែនដី និងការងារនគរបាលជាតិ ។

-ស្រាវជ្រាវ និងធ្វើការវិភាគ និងគ្រប់គ្រងការងារអាស៊ាន ដែលពាក់ព័ន្ធនឹងសមត្ថកិច្ច នៃក្រសួងមហាផ្ទៃ ។

-ធ្វើលិខិតជូនពរអោយថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ក្នុងឱកាសបុណ្យជាតិនិងអន្តរជាតិ ។

-បូកសរុបការងារ ប្រចាំអឌ្ឍមាស ខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ។

មាត្រា ៦ ._ រចនាសម្ព័ន្ធរបស់នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងអាស៊ាន រួមមាន ៖

-ការិយាល័យរដ្ឋបាល និង សរុប

-ការិយាល័យអាស៊ាន

-ការិយាល័យបកប្រែ

-ការិយាល័យអន្តរជាតិ

-ការិយាល័យពិធីការ

មាត្រា ៧ .- ការរៀបចំតួនាទី ភារកិច្ច និងការប្រព្រឹត្តទៅរបស់ការិយាល័យនីមួយៗ ចំពោះក្រុមអ្នកច្បាប់ និងនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងអាស៊ាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ។

**ជំពូកទី ៣**

**អវសានប្បញ្ញត្តិ**

មាត្រា ៨ .- បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៩ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ៨២ អនក្រ.តត**

**ស្តីពីការដាក់មន្ត្រីរាជការអោយចូលនិវត្តន៍**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/៩៤/០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញក្រឹត្យលេខ ១០.ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្ម ចំពោះនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ